**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រុមប្រឹក្សា**
**កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌**
**អង្គភាពគ្រប់គ្រងគម្រោង**

លេខៈ០០៧/០៩ក.ហ.អគគ

*រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ មីនា ឆ្នាំ២០០៩*

# កំណត់ហេតុ ស្តីពី ការបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា សិក្ខាសាលានៅសណ្ឋាគារអាំងទែរកុងទីណុងតាល់

ឆ្នាំពីរពាន់ប្រាំបួន ខែមីនា ថ្ងៃទីប្រាំមួយ វេលាម៉ោងប្រាំបី នៅសណ្ឋាគារអាំងទែរកុងទីណុងតាល់ មានរៀបចំ សិក្ខាសាលាមួយក្រោមអធិបតីភាពរបស់ឯកឧត្តម ស៊ុយ ម៉ុងលាង នាយកអង្គភាពគ្រប់គ្រងគម្រោង នៃក្រុមប្រឹក្សា កំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានការឧបត្ថម្ភពីកិច្ចសហប្រតិបត្តិការបរទេសអាឡឺម៉ង់ នៃកម្មវិធីកំណែ ទម្រង់រដ្ឋបាល និងវិមជ្ឈការ " អនុវត្តដោយអង្គការជីធីហ្សែត ( GTZ ) ស្តីពី " ការបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា "។

សមាសភាពអ្នកចូលរួមប្រជុំមានដូចបញ្ជីជូនភ្ជាប់ជាមួយ ។

ជាកិច្ចចាប់ផ្តើមឯកឧត្តម ស៊ុយ ម៉ុងលាង បានសម្តែងកិច្ចស្វាគមន៍ចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា តំណាងក្រសួង-ស្ថាប័នពាក់ព័ន្ធ និងភ្ញៀវអន្តរជាតិទាំងអស់ ដែលបានអញ្ជើញចូលរួមក្នុងអង្គ សិក្ខាសាលានាថ្ងៃនោះ ។ ឯកឧត្តមបានសម្តែងនូវ អំណរគុណចំពោះ អង្គការសហប្រតិបត្តិការអាឡឺម៉ង់ (GTZ) ដែលបាន ជួយឧបត្ថម្ភដល់ការអនុវត្តសកម្មភាព ជាអាទិភាព លេខ ១.៦.១ ដែលមានកំណត់នៅក្នុងផែនការសកម្មភាពសម្រាប់ការ អនុវត្តយុទ្ធសាស្រ្តកំណែទម្រង់ច្បាប់ និងតុលាការដែលគណៈរដ្ឋមន្ត្រីបានអនុម័តក្នុងសម័យប្រជុំពេញអង្គនា ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០០៥ ។ សិក្ខាសាលាស្តីពីការបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា ដែលយើងរៀបចំធ្វើនៅថ្ងៃនេះ គឺជា លទ្ធផល នៃការអនុវត្តគម្រោងមួយក្នុងចំណោមគម្រោងពីរទៀត គឺសិក្សាស្រាវជ្រាវអំពីសមត្ថភាពតាក់តែងច្បាប់ នៅ តាមក្រសួង-ស្ថាប័ន និងគម្រោងការបោះពុម្ពចងក្រងច្បាប់ និងលិខិតបទដ្ឋានគតិយុត្តដែលក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ បានចុះអនុសារណៈយោគយល់គ្នាជាមួយ GTZ នៅឆ្នាំ២០០៨ កន្លងទៅ ។ គោលបំណងចំបង នៃអង្គសិក្ខាសាលា គឺដើម្បីផ្តល់នូវការយល់ដឹងឱ្យកាន់តែប្រសើរអំពីស្ថានភាពបច្ចុប្បន្ននៃការិយាល័យទទួលពាក្យបណ្តឹងនៅតាម បណ្តាក្រសួង-ស្ថាប័នក្នុងក្របខណ្ឌនៃវិវាទរវាងប្រជាពលរដ្ឋ និងរដ្ឋបាលសាធារណៈ និង

ពីទស្សនាទានអន្តរជាតិ នៃ ប្រព័ន្ធអំប៊ូស្មាន់ និងការរៀបចំប្រព័ន្ធត្រួតពិនិត្យ និងតាមដាន ការបំពេញការងារ ក៏ដូចជាការផ្តល់សេវាសាធារណៈរបស់ រដ្ឋបាលចំពោះសាធារណៈជន ។ ការសិក្សាបឋមស្តីពីប្រព័ន្ធអំប៊ូស្មាន់ និងការទទួលពាក្យបណ្តឹងនៅកម្ពុជា ដោយអង្គភាព គ្រប់គ្រងគម្រោងនៃក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ដោយមានជំនួយបច្ចេកទេសពីអង្គការ GTZ បានអនុវត្តរួចហើយ ដើម្បីពិនិត្យមើលលើស្ថានភាពបច្ចុប្បន្ន នៃការិយាល័យទទួលពាក្យបណ្តឹងរបស់ក្រសួង-ស្ថាប័នផ្សេងៗ ។

លោកស្រី Katharina Huebner មន្ត្រីកម្មវិធីកំណែទម្រង់រដ្ឋបាល និងវិមជ្ឈការរបស់កម្មវិធីកិច្ចសហប្រតិបត្តិការអាឡឺម៉ង់ (GTZ) បានថ្លែងអំណរគុណដល់ ឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាងកញ្ញា ដែលបានមកចូលរួម ក្នុងអង្គសិក្ខាសាលានេះ ។ លោកស្រីបានរំលឹកឡើងវិញអំពីគោលបំណង នៃអង្គសិក្ខាសាលាគឺ ដើម្បីពិនិត្យ និងពិភាក្សា ទៅលើប្រព័ន្ធអំប៊ូស្មាន់ និងការិយាល័យទទួលពាក្យបណ្តឹង ពិសេសជាងនេះទៅទៀតនោះ យើងត្រូវធ្វើឱ្យប្រសើរឡើង ចំពោះការផ្តល់សេវាប្រព័ន្ធអំប៊ូស្មាន់ និងការិយាល័យទទួលពាក្យបណ្តឹងនៅក្នុងប្រទេសកម្ពុជានេះ ដែលជាបំណងប្រាថ្នា របស់រាជរដ្ឋាភិបាលតាំងពីឆ្នាំ ២០០២ ដែលមាននៅក្នុងកម្មវិធី កំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការ ។

លោក Johannes Ferguson ទីប្រឹក្សាកំណែទម្រង់រដ្ឋបាលសាធារណៈអង្គការ GTZ បានធ្វើបទបង្ហាញអំពី ទស្សនាទាន និងយន្តការប្រព័ន្ធអំប៊ូស្មាន់អន្តរជាតិ តាមរយៈការបញ្ចាំងស្លាយ ដោយមានចែកជូនឯកសារ ស្តីពីការណែនាំ អំពីប្រព័ន្ធអំប៊ូស្មាន់យ៉ាងលំអិតដល់អង្គប្រជុំទាំងមូល ។

ឯកឧត្តម សួង លាងហៃ នាយករងអង្គភាពគ្រប់គ្រងគម្រោង និជាប្រធានក្រុមគម្រោងកិច្ចសហប្រតិបត្តិការ ជាមួយ GTZ បានធ្វើបទបង្ហាញអំពីការសិក្សាបឋមលើប្រព័ន្ធអំប៊ូស្មាន់ និងការិយាល័យទទួលពាក្យបណ្តឹងនៅកម្ពុជា តាមរយៈការបញ្ចាំងស្លាយ ដោយមានចែកជូន ជាឯកសារដល់អង្គសិក្ខាសាលាទាំងមូលផងដែរ ។

ជាបន្ទាប់ មានវេទិកាសំណួរ-ចម្លើយ ដែលសម្របសម្រួលដោយឯកឧត្តមប្រធាន អង្គសិក្ខាសាលា ។

ឯកឧត្តមប្រធានបានបញ្ជាក់ថា ក្រោយពីបទបង្ហាញរបស់ឯកឧត្តម សួង លាងហៃ ឃើញថាមានការដាក់ឱ្យ ប្រើប្រាស់ខ្លះហើយនៅកម្ពុជា ដូចជាការិយាល័យទទួលពាក្យបណ្តឹងរបស់ប្រជាពលរដ្ឋនៅតាមក្រសួង-ស្ថាប័នមួយចំនួន ចំណែកក្រសួងខ្លះទៀតក៏មានគំនិតផ្តួចផ្តើមនឹងបង្កើតដែរ ។ ឯកឧត្តមបានស្នើសុំឱ្យអង្គសិក្ខាសាលាចូលរួមពិភាក្សា និង ផ្តល់មតិយោបល់ទាក់ទងនឹងអំប៊ូស្មាន់នេះ ។

លោក សុំ សុខាំឃួន មន្ត្រីរាជបណ្ឌិតសភាវិជ្ជាជីវៈតុលាការ លោកមានយោបល់ថា ពាក្យអំប៊ូស្មាន់នេះ គួរតែប្រែជា ការិយាល័យទទួលបណ្តឹង ឬមន្ទីរគាំពារបណ្តឹងប្រជាពលរដ្ឋ ។

លោកបានគាំទ្រចំពោះការបង្កើតអំប៊ូស្មាន់ ដែលអាចជួយផ្តួចផ្តើមធ្វើការអង្កេតទៅលើរដ្ឋបាលសាធារណៈ ហើយ លោកសូមកោតសរសើរចំពោះលទ្ធផល នៃការខិតខំស្រាវជ្រាវ ។ លោកយល់ឃើញថា ជម្រើសទី៣ គឺការបង្កើតក្រុម ប្រឹក្សាមានលក្ខណៈល្អប្រសើរ ហើយប្រហែលជាត្រូវនឹងបរិបទ និងស្ថានភាពរបស់កម្ពុជាយើង ។

ឯកឧត្តម ហេង សុខឃៀង អនុប្រធានគណៈកម្មការសិទ្ធិមនុស្ស (ACU) មានចំណាប់អារម្មណ៍ថា ជាលើក ទីមួយហើយដែលលោកបានចូលរួមធ្វើសិក្ខាសាលាស្តីពី ៉ការបញ្ចូលប្រព័ន្ធអំប៊ូស្មាន់នៅកម្ពុជា ៉ ។ លោកបានស្នើឱ្យមាន ការពន្យល់បន្ថែមទៀតឱ្យបានច្រើនដង អំពីប្រព័ន្ធអំប៊ូស្មាន់នេះ ។

លោក Johannes Ferguson បានបញ្ជាក់ថា មិនមែនជាការងាយស្រួលនោះទេ ក្នុងការពន្យល់អោយបានក្បោះ ក្បាយនោះ ។ ឯកឧត្តមប្រធានបានបន្ថែមទៀតថា ប្រព័ន្ធអំប៊ូស្មាន់មានសារៈសំខាន់ណាស់ ហើយយន្តការនេះទៀតសោត នៅខាងដាណឺម៉ាក របាយការណ៍របស់អំប៊ូស្មាន់ ត្រូវបានទទួលការគាំទ្រយ៉ាងខ្លាំងពីផ្នែកតុលាការ ។ ប៉ុន្តែចំពោះអំប៊ូស្មាន់ ក្នុងបរិបទកម្ពុជា ឯកឧត្តមនៅមិនទាន់ដឹងថា នឹងអាចទទួលជោគជ័យ និងមានប្រសិទ្ធភាពដូចគេដែរឬទេ ? ហេតុដូចនេះ ហើយ បានជាយើងធ្វើសិក្ខាសាលានេះឡើង ដើម្បីស្វែងរកគំនិតយោបល់ផ្សេងៗ និងរៀបជាទស្សនាទានឡើង ។ ឯកឧត្តមបានបំភ្លឺបន្ថែមចំពោះលោកស្រី Katharina Huebner ថាឯកឧត្តមមិនទាន់ធ្វើនៅឡើយទេ ទាក់ទងនឹងរដ្ឋបាល តុលាការ ហើយអំប៊ូស្មាន់នេះ គ្រាន់តែជាការបំពេញបន្ថែមទៅលើយន្តការដែលមានស្រាប់ ប៉ុន្តែមិនមែនបានគ្របដណ្តប់ទៅលើរដ្ឋបាលតុលាការទេ ។

លោកតំណាងខាងក្រសួងពត៌មាន មានយោបល់មួយចំនួនគាំទ្រចំពោះការបង្កើត ប្រព័ន្ធអំប៊ូស្មាន់នេះ ហើយចំពោះ យន្តការដែលបង្កើតប្រព័ន្ធនេះ គឺធ្វើយ៉ាងណាឱ្យខិតជិតប្រជាពលរដ្ឋ និងងាយស្រួលក្នុងការស្រង់យកការពិតពីប្រជាពលរដ្ឋ
ដើម្បីធ្វើការដោះស្រាយប្រកបដោយយុត្តិធម៌ជូនពួកគាត់ ។

លោក សូ សុវណ្ណា អនុប្រធានអធិការដ្ឋាន នៃក្រសួងមហាផ្ទៃ ជាអ្នកធ្វើការផ្ទាល់នៅក្នុងគម្រោងសិទ្ធិទទួល បាននូវយុត្តិធម៌ លោកបានស្នើឱ្យកែពាក្យ " មជ្ឈមណ្ឌលសេវាកម្មយុត្តិធម៌ ( ក្រសួងយុត្តិធម៌) " សូមឱ្យលុបពាក្យ ( ក្រសួង យុត្តិធម៌) ចេញពីក្នុងរបាយការណ៍ "ការសិក្សា

បឋមស្តីពីប្រព័ន្ធអំប៊ូស្មាន់ និងការទទួលពាក្យបណ្តឹងនៅកម្ពុជា "នៅទំព័រទី១០ បន្ទាត់ទី០៥ ។ ចំណុចមួយទៀតពាក់ព័ន្ធនឹងអគ្គាធិការ និងមុខងាររបស់អធិការកិច្ច ក្រសួងយុត្តិធម៌ និងក្រសួងមហាផ្ទៃ ជាអ្នកទទួលខុសត្រូវលើតួនាទីនេះ ។ ហើយកន្លងមកក្រសួងមហាផ្ទៃបានទទួលភារៈកិច្ច ដូចជា ការចុះអធិការកិច្ចនៅតាម ស្ថាប័នពាក់ព័ន្ធ និងដោះស្រាយបណ្តឹងរបស់ប្រជាពលរដ្ឋ ជាដើម។ លោកយល់ឃើញថា ប្រព័ន្ធអំប៊ូស្មាន់នេះមានលក្ខណៈ ស្របគ្នា និងស៊ីសង្វាក់គ្នាទៅនឹងការងារ អគ្គាធិការនោះដែរ ។

តំណាងក្រសួងទំនាក់ទំនងព្រឹទ្ធសភា និងអធិការកិច្ច បានចូលរួមយោបល់ថា ឈ្មោះអំប៊ូស្មាន់ នេះ ត្រូវដាក់ថា ការិយាល័យទទួលពាក្យបណ្តឹង និងអង្កេតស្រាវជ្រាវប្រជាពលរដ្ឋ ។ តួនាទី ការិយាល័យនេះ ត្រូវធ្វើយ៉ាងណាដាក់នៅជិត កន្លែងដែលប្រជាពលរដ្ឋងាយស្រួលធ្វើការទំនាក់ទំនង ហើយត្រូវផ្សព្វផ្សាយឱ្យបានស៊ីជម្រៅដល់ប្រជាពលរដ្ឋ ។ លោក បានគាំទ្រយ៉ាងពេញទំហឹងចំពោះ ការបង្កើតប្រព័ន្ធអំប៊ូស្មាន់នេះ រឹតតែឆាប់គឺ រឹតតែល្អ ។

ឯកឧត្តម គង់ សេង ទីប្រឹក្សាក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ មានចំណាប់អារម្មណ៍ថា តាមយោបល់ របស់ឯកឧត្តមផ្ទាល់ប្រព័ន្ធអំប៊ូស្មាន់នេះ គួរតែយកតាមប្រទេសអាឡឺម៉ង់ ឬគួរតែដាក់ តួនាទី និងឋានៈឱ្យខ្ពស់សម្រាប់ អ្នកធ្វើការងារអំប៊ូស្មាន់នេះ អោយមានសិទ្ធិអំណាចយ៉ាងពេញលេញ ក្នុងការត្រួតពិនិត្យគ្រប់ជាន់ថ្នាក់ និងគ្រប់ខេត្ត-ក្រុង ទាំងអស់ ។ មួយវិញទៀតលោកបានមាន ប្រសាសន៍ទៀតថា ពាក្យអំប៊ូស្មាន់នេះប្រែថា " ទទួលពាក្យបណ្តឹងរបស់ប្រជា ពលរដ្ឋ " ដូច្នេះគួរតែមានលក្ខណៈឯករាជ្យផងដែរ ហើយជាចុងបញ្ចប់លោកបានគាំទ្រចំពោះការបង្កើត ប្រព័ន្ធ អំប៊ូស្មាន់នេះ នៅតាមបណ្តាក្រសួងទាំងឡាយ ។

ឯកឧត្តមប្រធានបានធ្វើការបូកសរុប ដោយបានមានប្រសាសន៍កោតសរសើរចំពោះមតិយោបល់ដ៏ មានសារៈប្រយោជន៍ និងបទពិសោធន៍ល្អៗ ដែលអង្គសិក្ខាសាលាបានលើកឡើងនាថ្ងៃនោះ ។ ឆ្លៀតក្នុងឱកាសនោះផងដែរ ឯកឧត្តមប្រធាន បានស្នើសុំឱ្យមានការរៀបចំធ្វើសិក្ខាសាលាលក្ខណៈ បែបនេះម្តងទៀត ដើម្បីប្រមូល និងដកស្រង់នូវអនុសាសន៍មកធ្វើ ឯកសារ ។

ជាចុងក្រោយឯកឧត្តមប្រធានបានថ្លែងអំណរគុណសារជាថ្មីចំពោះឯកឧត្តម លោកជំទាវ លោក លោកស្រី អ្នកនាង កញ្ញា ភ្ញៀវជាតិ និងភ្ញៀវអន្តរជាតិទាំងអស់ ដែលបានចូលរួមក្នុងអង្គសិក្ខាសាលា នាថ្ងៃនេះ ។

អង្គប្រជុំពិភាក្សានេះបានចប់សព្វគ្រប់នៅវេលាម៉ោងដប់ពីរថ្ងៃត្រង់នាថ្ងៃដដែល ។

បានឃើញ និងឯកភាព

នាយកអ.គ.គ                                                                                   អ្នកធ្វើរបាយការណ៍

ស៊ុយ ម៉ុងលាង                                        សេង វ៉ាន់ដា          ស៊ុន សិរីវុធ